ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៣៧ ប្រក.កសក.ប

# ប្រកាស
## ស្តីពី
## ការបង្កើតវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស /រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ៥៨៨ ប្រក.កសក.បុ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352. Fax : (855) 23 - 217 320

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ ចំណុះនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានថ្នាក់ស្មើនឹងមន្ទីរខេត្ត រាជធានី ។

**ប្រការ ២** : វិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គម្រោងកម្មវិធី សិក្សា ពិសោធ និងស្រាវជ្រាវលើការងារផលិតកម្មសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវលើការងារចិញ្ចឹមសត្វ ការបង្កាត់ពូជ ចំណី និងការផ្តល់ចំណីសត្វ
- ស្រាវជ្រាវ និងកំណត់ស្តង់ដាចំណីសត្វ បសុឱសថ និងប្រព័ន្ធផលិតកម្មសត្វ
- អភិរក្ស និងអភិវឌ្ឍធនធានសេនេទិចសត្វ
- វិភាគ ស្រាវជ្រាវ និងប្រើប្រាស់ធនធានសេនេទិចសត្វប្រកបដោយនិរន្តរភាព
- វិភាគ ពិសោធ ស្រាវជ្រាវដើម្បីវាយតម្លៃពូជ និងចំណីសត្វ
- សហការជាមួយស្ថាប័ន វិទ្យាស្ថាននានា ផ្នែកឯកជន អង្គការជាតិ និងអង្គការអន្តរជាតិ លើការងារសិក្សា ស្រាវជ្រាវ ពិសោធន៍ស្រាវជ្រាវផលិតកម្មសត្វ
- ចូលរួមបណ្តុះបណ្តាល បំពាក់បំប៉នសមត្ថភាពអំពីការងារបច្ចេកទេស ពិសោធ វិភាគ ស្រាវជ្រាវលើការងារផលិតកម្មសត្វ
- ទទួលភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលប្រគល់ឲ្យ ។

វិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ ដឹកនាំដោយនាយកម្នាក់ និងអមដោយនាយករងមួយចំនួនជាជំនួយការ ។

**ប្រការ ៣** : វិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ មានការិយាល័យចំនួន ៣ និងមានស្ថានីយ៍ពិសោធន៍ពូជសត្វចំនួន ៣ ដែលមានថ្នាក់ស្មើនឹងការិយាល័យចំណុះមន្ទីរកសិកម្មរាជធានី ខេត្ត រួមមាន៖

១-ការិយាល័យរដ្ឋបាល
២-ការិយាល័យស្រាវជ្រាវសេនេទិច និងពូជសត្វ
៣-ការិយាល័យស្រាវជ្រាវចំណីសត្វ
៤-ស្ថានីយពិសោធន៍ពូជគោ ក្របី
៥-ស្ថានីយពិសោធន៍ពូជជ្រូក
៦-ស្ថានីយពិសោធន៍ពូជបក្សី

**ប្រការ ៤** : តួនាទី និងភារកិច្ចរបស់ការិយាល័យ និងស្ថានីយពិសោធន៍ពូជសត្វនីមួយៗមានដូចតទៅ៖

៤.១ ការិយាល័យរដ្ឋបាល

- គ្រប់គ្រង និងចាត់ចែងកិច្ចការរដ្ឋបាល និងបុគ្គលិកក្នុងវិទ្យាស្ថាន
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ
- រៀបចំផែនការស្រាវជ្រាវ និងតាមដានកិច្ចការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបញ្ជីគណនេយ្យ និងថវិកាសម្រាប់ដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងថែរក្សាចលនទ្រព្យ អចលនទ្រព្យ សន្និធិ ឧបករណ៍សម្ភារៈ បរិក្ខារ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរបស់វិទ្យាស្ថាន
- ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រស្រាវជ្រាវលើការងារផលិតកម្មសត្វ
- គ្រប់គ្រង និងផ្តល់សេវាបណ្ណាល័យ និងមូលដ្ឋានទិន្នន័យសម្រាប់ការស្រាវជ្រាវផលិតកម្មសត្វ

- ទទួលបន្ទុកបណ្ណាល័យកណ្តាល ចងក្រងឯកសារនិងផ្សព្វផ្សាយ
- រៀបចំរបៀប និងកិច្ចការពិធីការរបស់វិទ្យាស្ថាន
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

៤.២ ការិយាល័យស្រាវជ្រាវសេនេទិច និងពូជសត្វ

- សិក្សា ស្រាវជ្រាវ លើការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសេនេទិចសត្វ
- ធ្វើការសិក្សាវាយតម្លៃជីវចម្រុះ ស្រាវជ្រាវ និងប្រើប្រាស់ធនធានសេនេទិចប្រកបដោយនិរន្តរភាព
- សិក្សា និងកំណត់ស្តង់ដាប្រព័ន្ធផលិតកម្មសត្វ
- សិក្សា ស្រាវជ្រាវអំពីជីវៈបច្ចេកវិទ្យា ម៉ូលេគុល ដើម្បីកែលំអប្រព័ន្ធផលិតកម្មសត្វ
- អភិវឌ្ឍបច្ចេកទេសសមស្របសម្រាប់វាយតម្លៃពូជសត្វ និងការបង្កាត់ពូជសត្វ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

៤.៣ ការិយាល័យស្រាវជ្រាវចំណីសត្វ

- វិភាគ និងស្រាវជ្រាវលើគុណភាពចំណីសត្វ សារធាតុចិញ្ចឹម សារធាតុផ្សំចំណីសត្វ សារធាតុបន្ថែម និងសុវត្ថិភាព
- សិក្សា និងកំណត់ស្តង់ដាចំណីសត្វ សារធាតុផ្សំ សារធាតុបន្ថែមសម្រាប់ផ្សំចំណីសត្វ និងបសុឱសថ
- សិក្សា ស្រាវជ្រាវប្រសិទ្ធភាពសេដ្ឋកិច្ច និងប្រសិទ្ធភាពនៃចំណីសត្វ
- រៀបចំឯកសារបច្ចេកទេសស្តីពីចំណីសត្វ និងការប្រើប្រាស់ចំណីសត្វ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

៤.៤ ស្ថានីយពិសោធន៍ពូជគោ ក្របី

- អនុវត្តការងារសិក្សា និងពិសោធស្រាវជ្រាវលើផលិតកម្មពូជគោ ក្របី
- សិក្សាវាយតម្លៃលើការកែលំអពូជ និងការបង្កាត់ពូជគោ ក្របី
- សិក្សាពីឥរិយាបថសត្វ និងភាពស៊ាំនៃពូជគោ ក្របីក្នុងបរិស្ថានតំបន់នីមួយៗ
- សិក្សាលើកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការបន្តពូជ និងការលូតលាស់របស់ពូជគោ ក្របី
- ធ្វើការសិក្សាពិសោធអំពីវាលស្មៅ និងដំណាំចំណីសត្វ ធនធានចំណីសត្វ និងចំណីសត្វផ្សំស្រេចរបស់គោ ក្របី
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

៤.៥ ស្ថានីយពិសោធន៍ពូជជ្រូក

- អនុវត្តការងារសិក្សា ស្រាវជ្រាវ ពិសោធលើផលិតកម្មពូជជ្រូក
- សិក្សាតម្លៃលើការកែលំអពូជ និងការបង្កាត់ពូជជ្រូក
- សិក្សាពីឥរិយាបថសត្វ និងភាពស៊ាំនៃពូជជ្រូកក្នុងបរិស្ថានតំបន់នីមួយៗ
- សិក្សាលើកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការបន្តពូជ និងការលូតលាស់របស់ពូជជ្រូក
- ធ្វើការសិក្សាពិសោធអំពីដំណាំចំណីសត្វ ធនធានចំណីសត្វ និងចំណីសត្វផ្សំស្រេច
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

៤.៦ ស្ថានីយពិសោធន៍ពូជបក្សី

- អនុវត្តការងារសិក្សា ពិសោធ ស្រាវជ្រាវលើផលិតកម្មពូជបក្សី

- សិក្សាពីឥរិយាបថ និងភាពស៊ាំនៃពូជបក្សីក្នុងបរិស្ថានតំបន់នីមួយៗ
- សិក្សាលើកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការបន្តពូជ និងការលូតលាស់របស់ពូជបក្សី
- ធ្វើការសិក្សា ពិសោធន៍អំពីចំណាំចំណីសត្វ ធនធានចំណីសត្វ និងចំណីសត្វផ្សំស្រេច
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឲ្យ ។

**ប្រការ ៥** : ការិយាល័យ និងស្ថានីយពិសោធន៍ពូជសត្វនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមភាពចាំបាច់ ។

ប្រធានការិយាល័យ និងប្រធានស្ថានីយពិសោធន៍ពូជសត្វ ត្រូវទទួលខុសត្រូវចំពោះមុខនាយកវិទ្យាស្ថាន នូវរាល់សកម្មភាពការងារ នៅក្នុងការិយាល័យ និងស្ថានីយពិសោធន៍ពូជសត្វ ។

អនុប្រធានការិយាល័យ និងអនុប្រធានស្ថានីយពិសោធន៍ពូជសត្វ ជាជំនួយការឲ្យប្រធាន ត្រូវបានប្រធានប្រគល់ការងារមួយចំនួនឲ្យទទួលបន្ទុក និងត្រូវទទួលខុសត្រូវចំពោះមុខប្រធានលើរាល់សកម្មភាពការងារ ហើយត្រូវរួមជាមួយប្រធានទទួលខុសត្រូវរាល់ការងារក្នុងការិយាល័យ និងស្ថានីយពិសោធន៍ពូជសត្វ ។

**ប្រការ ៦** : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងប្រធានអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១១

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- មន្ទីរកសិកម្មរាជធានី ខេត្ត
- ដូចប្រការទី ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបសម្ព័ន្ធនៃប្រកាសលេខ.......១៣៧.......ប្រក.កសក.ប ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០១១

## អង្គការលេខរបស់វិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

